# បង្កើនរយៈពេលអនុគ្រោះ

សូមគោរពជូន អតិថិជនទាំងអស់! អតិថិជនជាច្រើនបានប្រាប់មកកាន់យើងខ្ញុំថា វិបត្តិ COVID-19 បានផ្តល់ផលប៉ះពាល់ដល់ផ្នែកហិរញ្ញវត្ថុរបស់លោកអ្នក។ ដូច្នេះ ដើម្បីជាជំនួយទៅកាន់អតិថិជនទាំងអស់ យើងខ្ញុំមានសេចក្តីសោមនស្សរីករាយក្នុងការប្រកាសថា ចាប់ពីថ្ងៃនេះតទៅ យើងខ្ញុំនឹងបង្កើនរយៈពេលអនុគ្រោះ ដែលអនុញ្ញាតឲ្យលោកអ្នកមានពេលបន្ថែមក្នុងការមិនចាំបាច់ទូទាត់បុព្វលាភធានារ៉ាប់រងមកកាន់ក្រុមហ៊ុនពី 30 ថ្ងៃទៅ 60 ថ្ងៃ ដោយពុំមានការប៉ះពាល់ដល់អត្ថប្រយោជន៍ធានារ៉ាប់រងរបស់លោកអ្នកនោះឡើយ។

នេះមានន័យថា បន្ទាប់ពីកាលបរិច្ឆេទដល់កាលកំណត់បង់បុព្វលាភធានារ៉ាប់រង អតិថិជនដែលបានជាវផលិតផលធានារ៉ាប់រងក្នុងចំណោមផលិតផលធានារ៉ាប់រងដែលមានសុពលភាពអនុវត្តសម្រាប់ការផ្តល់ជូននេះ ត្រូវបានអនុញ្ញាតឱ្យមានរយៈពេល 60 ថ្ងៃ (ដែលកាលពីមុនមានត្រឹមតែ 30 ថ្ងៃប៉ុណ្ណោះ) ដើម្បីទូទាត់នូវបុព្វលាភធានារ៉ាប់រងមកកាន់ក្រុមហ៊ុន។ ក្នុងអំឡុងពេលនេះ អតិថិជនក៏នៅតែអាចទទួលបានការការពារពេញលេញក្រោមបណ្ណសន្យារ៉ាប់រងរបស់ខ្លួនដដែល។

ផលិតផលធានារ៉ាប់រងដែលមានសុពលភាពអនុវត្តសម្រាប់ការផ្តល់ជូននេះ រួមមានផលិតផល PRUអនាគតកូនខ្ញុំ, PRUទ្រព្យខ្ញុំ, SafeLife, edusave, PRU MyFamily, easylife, កម្ចីមានសុវត្ថិភាព និងផលិតផលធានារ៉ាប់រងបន្ថែមដែលបានជាវភ្ជាប់ជាមួយនឹងផលិតផលធានារ៉ាប់រងខាងលើនេះ។

ប្រសិនបើលោកអ្នកត្រូវការព័ត៌មានបន្ថែម សូមទាក់ទងមកកាន់យើងខ្ញុំតាមរយៈ 023 964 222  ឬ 1800-212223 (ឥតគិតថ្លៃ)។

# Grace Period Extension

Dear customers, many of you told us that COVID-19 has been hard on your finances. Therefore, to support you we are pleased to announce that starting from today, we are extending the grace period allowing  you more time to not pay premium to the company without affecting your benefits from 30 days to 60 days.

This would mean that after premium due date, customers who have policies of the eligible products will be allowed 60 days (which was only 30 days previously) to pay the due premium for these policies. During this period, customers are still entitled to enjoy full protection under their policy.

Eligible products are PRUអនាគតកូនខ្ញុំ, PRUទ្រព្យខ្ញុំ, SafeLife, edusave, PRU MyFamily, easylife, កម្ចីមានសុវត្ថិភាព, and the attaching riders of the mentioned base plans.

If you need help, please contact us at 023 964 222 or 1800-212223 ( free of charge).